មាត្រា ១៨ ._

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ៣១ខែ ឧសភា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូនសម្តេច

នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ហត្ថលេខា

ពេជ្រ ប៊ុនធិន

★★★

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ២៧ អនក្រ.បក
### ស្តីពីការបង្កើតគណកម្មាធិការជាតិរៀបចំកម្មវិធីជាតិនៃសកម្មភាពអតិខឡន់កម្ពុជា

****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការ ប្រព្រឹត្តិទៅរបស់ក្រសួងផែនការ

យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

**សំរេច**

**មាត្រា ១ ._**

បង្កើតគណកម្មាធិការជាតិរៀបចំកម្មវិធីជាតិនៃសកម្មភាពអភិវឌ្ឍន៍កម្ពុជា ដែលហៅកាត់ថា គ.ជ.ស.ជ ដើម្បីគ្រប់គ្រងការរៀបចំឯកសារសំរាប់ចូលរួមប្រជុំសន្និសីទសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និង ការអភិវឌ្ឍន៍ ហៅ UNCTAD ។

**មាត្រា ២ ._**

គ.ជ.ស.ជ មានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងផែនការ | ជាប្រធាន |
| ២-ឯកឧត្តមរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ជាអនុប្រធាន |
| ៣-ឯកឧត្តមអគ្គលេខាធិការ ក.ក.ក | ជាអនុប្រធាន |
| ៤-ឯកឧត្តមរដ្ឋលេខាធិការក្រសួងផែនការ | ជាអនុប្រធានអចិន្ត្រៃយ៍ |
| ៥-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ៦-តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ជាសមាជិក |
| ៧-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៨-តំណាងក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៩-តំណាងក្រសួង បរិស្ថាន | ជាសមាជិក |
| ១០-តំណាងក្រសួង រៀបចំដែនដី នគរូបនីយកម្មនិងសំណង់ | ជាសមាជិក |
| ១១-តំណាងក្រសួង ធនធានទឹក និងឧតុនិយម | ជាសមាជិក |
| ១២-តំណាងក្រសួងទេសចរណ៍ | ជាសមាជិក |
| ១៣-តំណាងក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល | ជាសមាជិក |
| ១៤-តំណាងក្រសួង សាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| ១៥-តំណាងក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍ | ជាសមាជិក |
| ១៦-តំណាងក្រសួង សុខាភិបាល | ជាសមាជិក |
| ១៧-តំណាងក្រសួង អប់រំ យុវជន និងកីឡា | ជាសមាជិក |

១៨-តំណាងក្រសួង អភិវឌ្ឍន៍ជនបទ ជាសមាជិក

១៩-តំណាងក្រសួង កសិកម្ម រុក្ខាប្រមាញ់និងនេសាទ ជាសមាជិក

២០-តំណាងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទាជាសមាជិក

២១-តំណាង កិច្ចការនារី និង អតីតយុទ្ធជន ជាសមាជិក

២២-តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជាសមាជិក

២៣-ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងផែនការ លេខាធិការ

មាត្រា ៣ ._

គ.ជ.ស.ជ មានភារកិច្ចដូចតទៅ :

-សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំឯកសារកម្មវិធីជាតិនៃសកម្មភាពក្នុងការស្តារឡើងវិញការកសាងនិងអភិវឌ្ឍន៍កម្ពុជាស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

-ធ្វើទំនាក់ទំនងផ្ទាល់ជាមួយអគ្គលេខាធិការ UNCTAD និងអង្គការអន្តរជាតិនានាដើម្បីដោះស្រាយការងារពាក់ព័ន្ធ

-រាយការណ៍អំពីលទ្ធផលការងារនិងផ្តល់យោបល់ជាយុទ្ធសាស្ត្រ ដើម្បីសុំសេចក្តីសំរេចពីរាជរដ្ឋាភិបាល ។

មាត្រា ៤ ._

សមាជិក គ.ជ.ស.ជ ត្រូវចូលរួមប្រជុំតាមការអញ្ជើញ និងក្រោមការដឹកនាំរបស់ប្រធាន ឬ អនុប្រធានក្នុងករណីអវត្តមានរបស់ប្រធាន ។ ក្នុងករណីសមាជិកណាម្នាក់មិនបានឆ្លើយតបនឹងការអញ្ជើញដោយជាប់រវល់ភារកិច្ចត្រូវចាត់តំណាងដែលមានសិទ្ធិសំរេច ឲ្យចូលរួមប្រជុំជំនួស ។

មាត្រា ៥ ._

គ.ជ.ស.ជ មានលេខាធិការដ្ឋានដែលមានទីតាំងនៅក្រសួងផែនការ ហើយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងផែនការក្នុងករណីចាំបាច់ និងមានសិទ្ធិអញ្ជើញវរជនមានការពិសោធន៍និងអ្នកជំនាញឯកទេសមកពីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធអោយចូលរួមប្រជុំការងារក្នុងឋានៈជាជំនួយការខាងផ្នែកបច្ចេកទេស ។

លេខាធិការដ្ឋាន គ.ជ.ស.ជ ត្រូវដឹកនាំដោយឯកឧត្តមរដ្ឋលេខាធិការក្រសួងផែនការ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ស.ជ ។

មាត្រា ៦ ._

គ.ជ.ស.ជ ត្រូវរៀបចំថវិកាដោយឡែកមួយដែលជាឧបសម្ព័ន្ធថវិការបស់ក្រសួងផែនការ ដើម្បីដំណើរការងារជាក់ស្តែង ។

មាត្រា ៧ ._

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយទៅនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៨ ._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការនិង តំណាងក្រសួងនិងរដ្ឋលេខាធិការដ្ឋានដែលមានចែងក្នុងមាត្រា២ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះឲ្យបានសំរេច ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ ២០០០

បានជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រី
ដើម្បីសុំហត្ថលេខា
រដ្ឋមន្ត្រីក្រសួងផែនការ
ចាយ ថន

នាយករដ្ឋមន្ត្រី
បាត្តលេខា និងត្រា
ហ៊ុន សែន

***

## អនុក្រឹត្យលេខ ២៨ អនក្រ.បក
## ស្ដីពីការបង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា

****

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- យោងតាមសភាពការណ៍ចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

### សំរេច

មាត្រា ១ ._ បង្កើតអាជ្ញាធរជាតិទេសចរណ៍កម្ពុជា ដែលមានសមាសភាពចំរុះមកពីបណ្ដាក្រសួងស្ថាប័ននានា ដើម្បីជួយរាជរដ្ឋាភិបាល និងក្រសួងទេសចរណ៍ ក្នុងការគ្រប់គ្រងដឹកនាំការអភិវឌ្ឍវិស័យទេសចរណ៍ទូទាំងប្រទេស ។

អាជ្ញាធរជាតិទេសចរណ៍កម្ពុជាមានអក្សរកាត់ថា " អជទក " ។

មាត្រា ២ ._ អាជ្ញាធរជាតិទេសចរណ៍កម្ពុជា រួមមានសមាសភាព :

| | | |
|---|---|---|
| ១-ឯកឧត្ដម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | | ជាប្រធាន |
| ២-សម្ដេចព្រះរាម នរោត្តម បុប្ផាទេវី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | ជាអនុប្រធាន |
| ៣-ឯកឧត្ដម វណ្ណ ម៉ូលីវណ្ណ ប្រធានអគ្គនាយកអាជ្ញាធរអប្សរា | | ជាអនុប្រធាន |
| ៤-ឯកឧត្ដម វ៉េង សិរីវុឌ្ឍ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | | ជាអនុប្រធាន |